នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **ខ្មែរ**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):13-Jun-2014, 13:44
CMS/CFO:Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ:/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ឯកសារស្នើឡើងដោយមេធាវីការពារក្ដីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២

---

ដាក់ដោយ៖

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

លោក Arthur VERCKEN

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Soumeya MEDJEBEUR

លោក Pierre TOUCHE

ផ្ញើជូន៖

**អង្គជំនុំជម្រះតុលាការ**សាលាដំបូង

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

កញ្ញា អ៊ូច ស្រីផាត

កញ្ញា សេង លីណា

កញ្ញា Cécile ROUBEIX

**មេធាវីនៃដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា**

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម នៅក្នុងសំណុំរឿង ០០២ ហើយបានកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២។[1]

២. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ នៅក្នុងក្របខណ្ឌនៃការរៀបចំសំណុំរឿង ០០២/០២ នេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគី *"ផ្តល់សំណៅបញ្ជីឯកសារដែលបានដែលបានដាក់ពីពេលមុន ហើយដែលបានធ្វើបច្ចុប្បន្នភាពរួចហើយនោះ"*[2] មិនឲ្យហួសពីថ្ងៃសុក្រ ទី៣០ ខែឧសភា រួមទាំងឯកសារនានាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ដែលអំណើះតទៅត្រូវបានចាត់ទុកជាស្វ័យប្រវត្តិថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសំណុំរឿងទីពីរ ០០២/០២។[3] អង្គជំនុំជម្រះបានប្រកាសថា *"ការស្នើសុំដាក់ឯកសារថ្មី ឬឯកសារបន្ថែម និងវត្ថុតាងថ្មី ឬវត្ថុតាងបន្ថែម ដែលមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿងទីពីរ ០០២/០១ ត្រូវដាក់ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង"*។[4]

៣. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ គ្រប់ភាគីទាំងអស់បានស្នើសុំឲ្យអង្គជំនុំជម្រះ បញ្ជាក់ថាវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង នឹងត្រូវបានយកមកអនុវត្តតែចំពោះវត្ថុតាងដែលស្នើឡើងថ្មីៗដោយភាគីណាមួយ បន្ទាប់ពីបើកសវនាការលើសំណុំរឿងទីពីរ ០០២/០២ ប៉ុណ្ណោះ គឺបន្ទាប់ពីសវនាការបឋម នាពេលខាងមុខប៉ុណ្ណោះ។[5]

៤. នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ គ្រប់ភាគីទាំងអស់បានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះ ក្នុងការ ១) មិនដាក់បញ្ចូលក្នុងបញ្ជីឯកសារភស្តុតាង នូវឯកសារដែលទទួលស្គាល់រួចហើយដោយ

---

[1] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ **E301/9/1**។

[2] ដីកាបង្គាប់ឲ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ **E305** ("ដីកាបង្គាប់ **E305**") កថាខណ្ឌទី ១១។

[3] ដីកាបង្គាប់ **E305** កថាខណ្ឌទី ១១ និងកំណត់សម្គាល់ជើងទំព័រលេខ ១២។

[4] ដីកាបង្គាប់ **E305** កថាខណ្ឌទី ១៤។

[5] សំណើរួមរបស់ភាគីសុំការបំភ្លឺ អំពីការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ **E307** ។

អង្គជំនុំជម្រះនៅក្នុងសំណុំរឿងទីពីរ ០០២/០២ និង ២) ដាក់ជាបឋមតែមួយភាសាផ្លូវការប៉ុណ្ណោះ ។[6]

៥. នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានច្រានចោលសំណើរបស់ភាគីដែលសុំមិនដាក់បញ្ចូលក្នុងបញ្ជីឯកសារភស្តុតាង នូវឯកសារដែលទទួលស្គាល់រួចហើយដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿងទីពីរ ០០២/០២។ អង្គជំនុំជម្រះបានអនុញ្ញាតឱ្យភាគីដាក់ជាបឋមនូវបញ្ជីឯកសាររបស់ខ្លួន តែមួយភាសាផ្លូវការ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤។[7]

៦. នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៤ អង្គជំនុំជម្រះបានច្រានចោលសំណើរបស់ភាគីពាក់ព័ន្ធនឹងការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនជម្រះក៏បានស្នើឲ្យភាគីដាក់សំណើតាមវិធាននេះ សម្រាប់ភស្តុតាងដែលភាគីមិនបានដាក់បញ្ចូលនៅក្នុងបញ្ជីបឋមរបស់ខ្លួនកាលពីឆ្នាំ២០១១។[8]

៧. នៅក្នុងកាលៈទេសៈនេះ មេធាវីការពារក្តី លោក ខៀវ សំផន ("មេធាវីការពារក្តី") សូមដាក់បញ្ជីឯកសាររបស់ខ្លួនដែលមិនទាន់ពេញលេញ សម្រាប់សំណុំរឿង ០០២/០២។ បញ្ជីនេះចែកចេញជាច្រើនប្រភេទ ដូចខាងក្រោម ៖

- ឯកសារដែលមេធាវីការពារក្តីបានស្នើឡើងកាលពីឆ្នាំ ២០១១ (ឧបសម្ព័ន្ធ IV-ក)
- ឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ - មានន័យថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ដែរ - ដែលពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញ ដែលមេធាវីការពារក្តីបានស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ (ឧបសម្ព័ន្ធ IV-ខ)។

---

[6] សំណើរួមពីភាគីជូនអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការដាក់ឡើងវិញនូវភស្តុតាងដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង ០០២/០២ និងភាសានៃការដាក់ឯកសារ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ **E305/1** ។

[7] សេចក្តីសម្រេចលើសំណើរួមទាក់ទងនឹងការដាក់ឡើងវិញ នូវភស្តុតាងដែលបានទទួលយករួចហើយសម្រាប់ប្រើប្រាស់នៅក្នុងសំណុំរឿង ០០២/០២ និងការដាក់ឯកសារមួយភាសា ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៤ **E305/2** (លោក Kenneth ROBERTS បានផ្ញើជូនជាពត៌មានដល់ភាគីនូវច្បាប់ចម្លងជាភាសាអង់គ្លេសនូវសេចក្តីសម្រេចនោះ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៤)។

[8] សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) (ឯកសារ E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (ឯកសារ E305/3) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ **E307/1** ។ ("សេចក្តីសម្រេចលើការអនុវត្តវិធាន ៨៧(៤) E307/1")។

- ឯកសារបន្ថែមពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញខាងលើនេះ (ឧបសម្ព័ន្ធ IV-គ)
- ឯកសារបន្ថែម ផ្សេងទៀត ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ (ឧបសម្ព័ន្ធ IV-ឃ)

**ឯកសារដែលមេធាវីការពារក្ដីបានស្នើនៅឆ្នាំ ២០១១ (ឧបសម្ព័ន្ធ IV-ក)**

៨. ឧបសម្ព័ន្ធ IV-ក រួមមានឯកសារដែលមេធាវីការពារក្ដីបានស្នើឡើងនៅឆ្នាំ២០១១។[9] ថ្វីត្បិតតែឯកសារខ្លះដែលស្នើឡើងនៅឆ្នាំ ២០១១ ត្រូវបានលុបចោលយ៉ាងណាក្ដី ក៏លំដាប់លំដោយនៃការបង្ហាញឯកសារនោះនៅដូចគ្នានឹងបញ្ជីកាលពីឆ្នាំ ២០១១ ដែរ។

៩. ដោយអនុលោមតាមការបង្គាប់របស់អង្គជំនុំជម្រះ[10] ឯកសារទាំងនេះត្រូវបានកំណត់អត្តសញ្ញាណ តាមរយៈលេខសម្គាល់បច្ចុប្បន្នរបស់វា ហើយពត៌មានបន្ថែមដែលបានស្នើឡើងត្រូវបានធ្វើបច្ចុប្បន្នភាព (លេខយោង ERN ទៅតាមភាសាដែលមាន សេចក្ដីសង្ខេប និងចំណុចនៅក្នុងដីកាបញ្ជូនឱ្យស៊ើបសួរដែលពាក់ព័ន្ធ) ។

**ឯកសារដែលបានដាក់ចំពោះមុខអង្គជំនុំជម្រះ ហើយដែលពាក់ព័ន្ធជាមួយអ្នកដែលបានស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ (ឧបសម្ព័ន្ធ IV-ខ)**

១០. ឧបសម្ព័ន្ធ IV-ខ រួមមានឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធនឹងបុគ្គលដែលមេធាវីការពារក្ដីបានស្នើសុំឱ្យកោះហៅសម្រាប់សំណុំរឿង ០០២/០២។[11]

១១. ដោយហេតុថា ឯកសារទាំងនេះត្រូវបានចាត់ទុកជាស្វ័យប្រវត្តិថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ និងដោយគិតទៅតាមពេលវេលាដែលផ្ដល់ជូន ក៏ដូចជាចំនួនឯកសារដ៏ច្រើនដែលទទួលស្គាល់ថា បានដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះ គេមិនអាចចាត់ទុកថា ឧបសម្ព័ន្ធនេះមានភាពពេញលេញនៅឡើយទេ។

---

[9] បញ្ជីឯកសារ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ **E9/29** ជាមួយនឹងឧបសម្ព័ន្ធ **E9/29.2**។

[10] ដីកាបង្គាប់ **E305** កថាខណ្ឌទី ១១ និងកំណត់សម្គាល់ជើងទំព័រលេខ ១១ និងលេខ ១២។

[11] សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្ដីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ **E305/5** ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ **E305/5.1** (បញ្ជីឈ្មោះ) និង **E305/5.2** (សេចក្ដីសង្ខេប)។

## ឯកសារបន្ថែម (ឧបសម្ព័ន្ធ IV-គ និង IV-ឃ)

១២. ឧបសម្ព័ន្ធ IV-គ និង IV-ឃ រួមមានឯកសារ « បន្ថែម » ក្នុងន័យថា គឺជាឯកសារដែលមេធាវីការពារក្ដីមិនដែលបានស្នើឡើងកាលពីឆ្នាំ២០១១ ហើយក៏មិនបានទទួលស្គាល់ថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០១ ដែរ។

១៣. ដូចគ្នានេះដែរ ឯកសារខ្លះមាននៅក្នុងសំណុំរឿង ០០២ ទាំងមូល ហើយអង្គជំនុំជម្រះ និងភាគី អាចប្រើប្រាស់បាន។ ឯកសារទាំងនោះ ១. ត្រូវបានដាក់បញ្ចូលក្នុង SMD (Shared Material Drive) ឬ ២. ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងស៊ើបអង្កេត (ដោយមានលេខកូដ D) ឬ ៣.ត្រូវបានស្នើឡើងដោយភាគីនៅក្នុងបញ្ជីបឋមរបស់ខ្លួនកាលពីឆ្នាំ ២០១១ ឬ ៤. ស្នើឡើងដោយភាគីនៅក្នុងអម្លុងពេលនៃសំណុំរឿង ០០២/០១។ ឯកសារទាំងនោះត្រូវបានបង្ហាញតាមលក្ខណៈដើមរបស់វា នៅក្នុងឧបសម្ព័ន្ធ IV-គ និង IV-ឃ។

១៤. ឯកសារផ្សេងទៀតមិនមានក្នុងសំណុំរឿងទេ តែវាស្ថិតក្នុងប្រភេទឯកសារសាធារណៈ។ ឯកសារទាំងនោះត្រូវបានបង្ហាញតាមលក្ខណៈដើមរបស់វា នៅក្នុងឧបសម្ព័ន្ធ IV-គ និង IV-ឃ និងដូចដែលបានភ្ជាប់មកជាមួយនឹងសំណេរនេះ។

១៥. ឯកសារទាំងអស់ក្នុងឧបសម្ព័ន្ធទាំងពីរនេះ ដែលមិនមានឈ្មោះក្នុងបញ្ជីបឋមរបស់ភាគីនានាកាលពីឆ្នាំ ២០១១[12] ត្រូវចាត់ទុកថា ទទួលយកបាន តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

១៦. ដោយអនុលោមតាមយុត្តិសាស្ត្រអង្គជំនុំជម្រះ ឯកសារទាំងនេះបង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងប្រភពព័ត៌មានផ្សេងទៀត ដែលបានដាក់បញ្ចូលក្នុងសំណុំរឿងរួចហើយ និង/ឬ ជាឯកសារដោះបន្ទុក ហើយដែលត្រូវតែយកមកពិនិត្យ ដើម្បីចៀសវាងកំហុសតាមផ្លូវតុលាការ។[13]

---

[12] សេចក្ដីសម្រេចលើការអនុវត្តវិធាន ៨៧(៤) E307/1 កថាខណ្ឌទី៥។ សេចក្ដីណែនាំពាក់ព័ន្ធនឹងឯកសារដែលភាគីស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ សម្រាប់គោលបំណងនៃការសួរផ្ទៀង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ E199 កថាខណ្ឌទី៣។

[13] សេចក្ដីសម្រេចលើការអនុវត្តវិធាន ៨៧(៤) E307/1 កថាខណ្ឌទី៣។ ជាឧទាហរណ៍ សូមអាន ៖ ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីក្នុងសំណុំរឿង ពាក់ព័ន្ធនឹងការផ្ដល់សក្ខីកម្មរបស់សាក្សី François PONCHAUD និង Sydney SCHANBERG (ឯកសារ E243) ព្រមទាំងអ្នកជំនាញ Philip SHORT (ឯកសារNº

១៧. ឯកសារ «បន្ថែម» ទាំងនេះ ត្រូវបានស្នើឡើងដោយមេធាវីការពារក្តី ដោយសារតែវាជាប់ពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មរបស់បុគ្គលទាំងឡាយ ដែលមេធាវីការពារក្តីបានស្នើសម្រាប់សំណុំរឿង ០០២/០២[14] (ឧបសម្ព័ន្ធ IV-គ) ឬដោយសារតែឯកសារទាំងនោះពង្រឹងបន្ថែមនូវមតិយល់ឃើញរបស់មេធាវីការពារក្តី និង/ឬ មានអត្ថប្រយោជន៍ សម្រាប់ការសួរបកទៅបុគ្គលទាំងឡាយដែលភាគីដទៃបានស្នើសម្រាប់សំណុំរឿង ០០២/០២ (ឧបសម្ព័ន្ធ IV-ឃ)។

១៨. ក្នុងទិសដៅនេះ មេធាវីការពារក្តីសូមបញ្ជាក់ថា ខ្លួនអាចនឹងពង្រីកបញ្ជីឯកសារឲ្យកាន់តែច្រើនឡើង នៅខណៈដែលខ្លួនអាចធ្វើការស្រាវជ្រាវបានល្អិតល្អន់ អាស្រ័យទៅតាមបុគ្គលដែលអង្គជំនុំជម្រះសម្រេចថា នឹងកោះហៅឲ្យមកផ្តល់សក្ខីកម្ម។

១៩. ម៉្យាងវិញទៀត នៅក្នុងសំណុំរឿង ០០២/០២ មេធាវីការពារក្តីសូមរក្សាសិទ្ធិប្រើប្រាស់ឯកសារទាំងអស់ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ហើយដែលត្រូវបានទទួលស្គាល់ថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ដែរនោះ។

**<u>អំពីលេខកូដឯកសារ ERN ដែលមានចុះនៅក្នុងឧបសម្ព័ន្ធទាំងបួន</u>**

២០. អង្គជំនុំជម្រះដែលបានស្នើសុំឲ្យភាគីបញ្ជាក់ «តាមតែអាចធ្វើទៅបាន» នូវសម្រង់សម្តីដែលមានភាពពាក់ព័ន្ធ ពីក្នុងសៀវភៅ ឬឯកសារដែលមានចំនួនច្រើនទំព័រដទៃទៀត[15] មេធាវីការពារក្តីបានធ្វើអស់ពីលទ្ធភាពទៅតាមពេលវេលាដែលបានបែងចែក។ នៅក្នុងដំណាក់កាលនេះ សម្រង់សម្តីដែលបានដាក់បញ្ចូលនេះមានលក្ខណៈមិនពេញលេញ ដែលនឹងត្រូវសម្របទៅតាមការអះអាងរបស់សាក្សីនៅក្នុងសវនាការ។

---

E226, 226/1 និង E230) និង Elizabeth BECKER (ឯកសារNº E232 និងE232/1) ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ **E260** កថាខណ្ឌទី៥។

[14] សាក្សី និងអ្នកជំនាញស្នើឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន សម្រាប់សំណុំរឿង ០០២/០២ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៤ **E305/5** ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ **E305/5.1** (បញ្ជីឈ្មោះ) និង **E305/5.2** (សេចក្តីសង្ខេប)។

[15] ដីកាបង្គាប់ **E305** កថាខណ្ឌទី ១១ និងកំណត់សម្គាល់ជើងទំព័រលេខ ១១។

២១. ម្យ៉ាងវិញទៀត មេធាវីការពារក្តីសូមបញ្ជាក់ថា ខ្លួនបានភ្ជាប់ទៅនឹងសំណោរនេះនូវឯកសារដែលរហូតមកដល់ពេលនេះមិនទាន់បានចុះលេខ ERN នៅឡើយ។ ចំពោះសៀវភៅ ឬឯកសារដែលមានច្រើនទំព័រ មេធាវីការពារក្តីសូមភ្ជាប់តែសម្រង់ណាដែលយល់ថា មានភាពពាក់ព័ន្ធតែប៉ុណ្ណោះ។

**អំពីភាពជាប់ពាក់ព័ន្ធនៃឯកសារដែលមានចុះក្នុងឧបសម្ព័ន្ធទាំង៤**

២២. ក្នុងការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ អង្គជំនុំជម្រះបានបង្ហាញថា ៖

"នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានស្តាប់ភស្តុតាងដែលពាក់ព័ន្ធ និងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធ ទំនាក់ទំនងរដ្ឋបាល និងយោធា គោលនយោបាយសហឧក្រិដ្ឋកម្មរួម និងតួនាទី និងអត្តចរិតរបស់ជនជាប់ចោទ។ ភស្តុតាងដែលបានដេញដោលនេះក្លាយជាមូលដ្ឋានគ្រឹះសម្រាប់សវនាការលើអង្គហេតុនានា ដែលនៅសេសសល់ក្នុង សំណុំរឿង ០០២។ ទោះជាយ៉ាងណាក្តី បញ្ហាមួយចំនួនដែលបានលើកឡើងខាងលើនេះ មិនត្រូវបានយកមកពិនិត្យបានពេញលេញ ក្នុងសំណុំរឿង ០០២/០១ ទេ ដោយសារវិសាលភាពរបស់វាមានកម្រិត ហើយអាចពាក់ព័ន្ធនឹងបរិបទក្នុងសំណុំរឿង០០២/០២ ដែរ។ ហេតុនេះ ផ្នែកទាំងនេះនៃដីកាដំណោះស្រាយត្រូវបានបញ្ចូលយ៉ាងទូលំទូលាយទៅក្នុងវិសាលភាពសំណុំរឿង ០០២/០២ ដោយសារផ្នែកទាំងនេះ មានការចោទប្រកាន់អង្គហេតុដែលពាក់ព័ន្ធនឹង សំណុំរឿង ០០២/០២ នេះ ហើយ មិនធ្លាប់ត្រូវបានយកមកពិនិត្យឲ្យបានពេញលេញនៅឡើយ"។[16]

២៣. នាពេលថ្មីៗនេះ មេធាវីការពារក្តីបានធ្វើការស្នើសុំឲ្យអង្គជំនុំជម្រះបញ្ជាក់ពីអ្វីដែលអង្គជំនុំជម្រះចាត់ទុកថា មិនទាន់បានពិនិត្យមួយផ្នែកឬទាំងស្រុង កាលពីក្នុងសំណុំរឿង ០០២/០១។[17]

២៤. ដោយសារតែនៅរង់ចាំសេចក្តីបញ្ជាក់មួយ ដែលអាចឲ្យខ្លួនធ្វើការជ្រើសរើសបានត្រឹមត្រូវនោះ មេធាវីការពារក្តីសូមស្នើដាក់ឯកសារពាក់ព័ន្ធនឹងផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទិននឹងសំណុំរឿង ០០២/០១ ដែលត្រូវបានដាក់បញ្ចូលជាថ្មី ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២។

---

[16] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ E301/9/1 កថាខណ្ឌទី ៤២។

[17] សេចក្តីជំទាស់របស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះការសុំឲ្យកោះហៅបុគ្គលមួយចំនួនដែលស្នើមកផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២/០២ និងសំណើសុំការបំភ្លឺលើវិសាលភាពជាក់លាក់នៃការពិភាក្សាដេញដោលបន្ទាប់ពីសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង E301/9/1 ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ **E305/9**។

២៥. មេធាវីការពារក្តីសូមលើកឡើងដដែលៗ ពីភាពចាំបាច់នៃចម្លើយបំភ្លឺច្បាស់លាស់របស់អង្គជំនុំជម្រះ។ បើគ្មានចម្លើយនោះទេ ភាគីនឹងមិនអាចធ្វើការជំទាស់លើឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងឆ្លើយតបនឹងការជំទាស់នានាលើភាពពាក់ព័ន្ធបានឡើយ (វិធាន ៨៧(៣) ក នៃវិធានផ្ទៃក្នុង)។

២៦. **អាស្រ័យហេតុនេះ** ក្រុមមេធាវីការពារក្តី របស់ លោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះមេត្តា ៖

- **ធ្វើការបំភ្លឺ** លើវិសាលភាពជាក់លាក់នៃការពិភាក្សាដេញដោលដែលជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ ដោយបញ្ជាក់អំពីអ្វីដែលអង្គជំនុំជម្រះចាត់ទុកថា មិនទាន់បានពិនិត្យពេញលេញ មួយចំណែក ឬទាំងស្រុង នៅក្នុងសំណុំរឿង ០០២/០១
- **ប្រកាសទទួលយក** ឯកសារដែលស្នើឡើងសម្រាប់សំណុំរឿង ០០២/០២ ដូចដែលមាននៅក្នុងឧបសម្ព័ន្ធ ពី IV-ក រហូតដល់ IV-ឃ។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br>មេធាវី Anta GUISSÉ<br>មេធាវី Arthur VERCKEN | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |